**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.០០១.......សហវ.ណ.ជ

ថ្ងៃ សុក្រ ១៣កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០២០

# សារាចរណែនាំ
# ស្តីពី
# ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- យោងព្រះរាជក្រមលេខនស/រកម/១២១៩/០២៥ ចុះថ្ងៃសុក្រ ០៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងប្រកាសលេខ ១៤២៩ សហវ.ប្រក ចុះថ្ងៃ ចន្ទ ០៥កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវ នឹងថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងការសម្រេចដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០២០ ។

ផ្អែកលើសភាពការណ៍វិបត្តិថ្មីនៃសេដ្ឋកិច្ចសកល ពិសេសការផ្ទុះរីករាលដាលនូវជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (COVID-19) ដែលបណ្តាលឱ្យមានផលប៉ះពាល់ដល់ក្របខណ្ឌច្បាប់ថវិកាឆ្នាំ ២០២០ ជាទូទៅ និង តម្រូវឱ្យរាជរដ្ឋាភិបាលត្រូវធ្វើវិចារណកម្មថវិកាឡើងវិញ ដោយផ្តោតអាទិភាពពិសេសលើការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺ COVID-19 និងទប់ទល់ផលប៉ះពាល់អវិជ្ជមានមកលើសេដ្ឋកិច្ចជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី ខេត្ត និង រដ្ឋបាលរាជធានី ខេត្ត នូវវិធានការសម្រាប់ការអនុវត្តចំណាយថវិកាឆ្នាំ ២០២០ ដូចខាងក្រោម ៖

**១. ការធ្វើវិចារណកម្មចំណាយ**

- ពង្រឹងការគ្រប់គ្រងចំណាយបន្ទុកបុគ្គលិកឱ្យបានម៉ឺងម៉ាត់បំផុត ដោយអនុវត្តគោលការណ៍រើសថ្មី ត្រឹមស្មើនឹងចំនួនចូលនិវត្តន៍ ពោលគឺរក្សាចំនួនក្របខណ្ឌមន្ត្រីរាជការស៊ីវិល យោធា និងនគរបាល ដូចនៅក្នុងឆ្នាំ ២០១៩ ។
- ធ្វើវិចារណកម្មចំណាយពីមុខសញ្ញាចំណាយមួយចំនួន ដែលមិនទាន់ចាំបាច់ ឬមិនទាន់ចាំបាច់ខ្លាំង, មិនសូវប៉ះពាល់សកម្មភាពការងារ, និងមានសមាសធាតុនាំចូលខ្ពស់ ឬទាំងស្រុង ដើម្បីយកទៅបំពេញមុខចំណាយចាំបាច់ថ្មីៗ ក្នុងនោះ ៖

<u>ក្រសួង ស្ថាប័ន រដ្ឋបាលកណ្តាល</u>

- កាត់សន្សំចំណាយបេសកកម្មក្រៅប្រទេស ៥០% ចំពោះក្រសួង ស្ថាប័នទាំងអស់, លើកលែងតែ ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងពាណិជ្ជកម្ម ដែលត្រូវបានកាត់សន្សំត្រឹម ២៥% ។
- កាត់សន្សំចំណាយលើសម្ភារៈការិយាល័យ ១៥% សម្រាប់ក្រសួង ស្ថាប័នទាំងអស់ ។
- កាត់សន្សំចំណាយសម្ភារ និងបរិក្ខារបច្ចេកវិទ្យាព័ត៌មានវិទ្យា ១៥% សម្រាប់ក្រសួង ស្ថាប័នទាំងអស់ ។
- កាត់សន្សំចំណាយប្រេងឥន្ធនៈ និង ប្រេងរំអិល ១៣% សម្រាប់ក្រសួង ស្ថាប័នទាំងអស់ ។
- ព្យួរការអនុវត្តរាល់ការទិញរថយន្តសម្រាប់បម្រើការងាររដ្ឋបាលរបស់ក្រសួង ស្ថាប័នទាំងអស់ លើកលែងតែការទិញរថយន្តអគ្គិភ័យ រថយន្តដឹកឱសថ ជាដើម ដើម្បីបំពេញតម្រូវការជាចាំបាច់ក្នុងការផ្តល់សេវាសាធារណៈ ។

<u>គ្រឹះស្ថានសាធារណៈរដ្ឋបាល</u>

- ព្យួរការអនុវត្តរាល់ការទិញរថយន្តសម្រាប់បម្រើការងាររដ្ឋបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ។
- កាត់សន្សំលើមុខចំណាយបេសកកម្មក្រៅប្រទេស ៥០%, សម្ភារៈការិយាល័យ ១៥%, សម្ភារ និងបរិក្ខារបច្ចេកវិទ្យាព័ត៌មានវិទ្យា ១៥% របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលទទួលឧបត្ថម្ភធន ១០០% ពីថវិកាជាតិ ។ ដោយឡែក គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលទទួលបានឧបត្ថម្ភធនពីថវិកាជាតិមួយផ្នែកសម្រាប់បំពេញតុល្យភាពចំណូល-ចំណាយប្រចាំឆ្នាំ ត្រូវបានអនុញ្ញាតឱ្យ

ប្រើប្រាស់ថវិកាក្នុងកម្រិតតុល្យភាពរបស់ខ្លួន ប៉ុន្តែនឹងមិនមានការបន្ថែមថវិកាជូនទេ ក្នុងករណីចំណូលផ្ទាល់មានការថយចុះ ។

<u>មន្ទីរជំនាញរាជធានី ខេត្ត</u>

- ព្យួរការអនុវត្តរាល់ការទិញរថយន្តសម្រាប់បម្រើការងាររដ្ឋបាលរបស់មន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ។

<u>រដ្ឋបាលរាជធានី ខេត្ត</u>

- ត្រូវតម្រឹម ឬ កាត់បន្ថយចំណាយជាស្វ័យប្រវត្តិទៅតាមការធ្លាក់ចុះនៃចំណូលចរន្តរបស់ខ្លួន ដើម្បីរួមចំណែកចែករំលែកការលំបាកជាមួយថ្នាក់ជាតិ ។
- កាត់បន្ថយចំណាយវិនិយោគលើមុខសញ្ញាដែលមិនទាន់ចាំបាច់ និង មិនចូលរួមចំណែកផ្ទាល់ដល់ការជំរុញកំណើនសេដ្ឋកិច្ច ។

## ២. ការជំរុញ និងពង្រឹងប្រសិទ្ធភាពចំណាយ

- ពង្រឹងប្រសិទ្ធភាពប្រតិបត្តិការចំណាយ ទាំងការលើកកម្ពស់តម្លៃលុយ យថាប្រភេទ បរិមាណ និងទាំងប្រសិទ្ធភាពបច្ចេកទេស ។
- តម្រង់ការអនុវត្តចំណាយឱ្យចំទិសដៅដែលបានកំណត់ ស្របតាមលទ្ធផលនៃការការពារគម្រោងថវិកា ។
- ទប់ស្កាត់ចំណាយដែលមិនចាំបាច់ ឬ ដែលមិនមានផលចំណេញ ឬ មិនមានផលប្រយោជន៍ច្បាស់លាស់សម្រាប់ក្រសួង ស្ថាប័នសម្រេចគោលដៅបេសកកម្មការងាររបស់ខ្លួន ។
- រឹតបន្តឹងចំណាយនៅតាមក្រសួង ស្ថាប័ន នីមួយៗ ដែលមិនមានផលដល់ការជំរុញការប្រើប្រាស់ក្នុងស្រុក ។
- ផ្អាកការទិញសម្ភារៈឧបករណ៍មិនបន្ទាន់ និងដែលមានចរិតជាការនាំចូល ព្រមទាំងផ្អាកការផ្តល់គោលការណ៍សាងសង់ថ្មីៗ លើកលែងតែការងារជួសជុលអគារដែលមានស្រាប់ ។
- ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងសន្និធិ និងការបែងចែកទំនិញ និងសេវា ក៏ដូចជាធនធានឱ្យដល់គោលដៅ ឬដល់ដៃ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពការងារ ។
- សម្រួលការអនុវត្តចំណាយឱ្យបានលឿន លើចំណាយការការពារ និងប្រយុទ្ធប្រឆាំងជំងឺ Covid-19, ចំណាយដើម្បីស្រូបយកផលប៉ះពាល់, ចំណាយអន្តរាគមន៍ទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងសភាពការណ៍វិវត្តន៍ជាក់ស្តែងឱ្យបានទាន់ពេលវេលា ។
- ផ្តោតអាទិភាពលើចំណាយថវិកាវិត្ថារកម្ម ដោយប្រើនីតិវិធីរួមសម្រាប់ការគ្រប់គ្រងគម្រោង (SOP) ដើម្បីរួមចំណែកដល់ការបង្កើតការងារផ្ទាល់ ការស្តារនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគកសាងមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច ។
- ជំរុញដៃគូអភិវឌ្ឍន៍ឱ្យពន្លឿនការអនុម័តគម្រោងដែលបានសិក្សាសមិទ្ធិលទ្ធភាពរួចរាល់ និងទទួលយកដោយរាជរដ្ឋាភិបាលកម្ពុជា ឱ្យឈានទៅដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងអនុវត្តគម្រោងឱ្យបានឆាប់ ។ ដោយឡែក ក្នុងដំណាក់កាលអនុវត្ត ជំរុញលើកកម្ពស់ប្រសិទ្ធភាពការងារ តាមដាន និងត្រួតពិនិត្យជាប្រចាំដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍រវាងស្ថាប័នអនុវត្តគម្រោង, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ។

ក្នុងការអនុវត្តនូវវិធានការដែលបានដាក់ចេញខាងលើ ក្រសួង ស្ថាប័នត្រូវកែតម្រូវទំហំឥណទានសរុបរួមទាំង **តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន** របស់ខ្លួន ទៅតាមទំហំនៃមុខសញ្ញាចំណាយទាំងអស់ដែលបានកាត់សន្សំខាងលើ និងទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពពាក់ព័ន្ធ ។

ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយដែលបានដាក់ចេញខាងលើ ត្រូវបានគិតគូររៀបចំឡើងក្នុងក្របខណ្ឌថវិកាវិត្តារកម្ម ដើម្បីបង្កើនតម្រូវការក្នុងស្រុក, ធានាប្រក្រតីភាពនៃស្ថាប័នរដ្ឋ និង រក្សាលំនឹងជីវភាពប្រជាជន ទន្ទឹមនឹងការសន្សំចំណាយ សម្រាប់យកទៅបំពេញឱ្យតម្រូវការចំណាយបន្ទាន់ចាំបាច់ក្នុងការការពារ និងប្រយុទ្ធប្រឆាំងនឹងជម្ងឺ Covid-19 ដើម្បីធានានូវប្រព័ន្ធសុខភាពសាធារណៈ ប្រកបដោយគុណភាព និង ការជឿទុកចិត្តនៅក្នុងប្រទេស ។

គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល៖</u>**

- អគ្គលេខាធិការដ្ឋានក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្ត
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ